ការិយាល័យរដ្ឋបាល ក្រ.សបរ៉េ
មកដល់ថ្ងៃទី 25/08 2021 ម៉ោង 15:00
លេខ: ............ សហវ
អ្នកទទួល: ............ ហត្ថលេខា ............
អ្នកប្រគល់: ............ ហត្ថលេខា ............

# ព្រះរាជក្រឹត្យ

នស/រកត/០៨២១/៥៦៤

## ស្តីពី

## ការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និង សង្គមឌីជីថល

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពី ការតែងតាំង និង ការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើត ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និង សង្គមឌីជីថល ដែលសរសេរជាអក្សរកាត់ថា **ក.ស.ឌ.** ជាសេនាធិការរបស់រាជរដ្ឋាភិបាល នៅក្នុងការដឹកនាំសម្របសម្រួល និង ការជំរុញការកសាង និង ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថលរស់រវើក តាមរយៈការរៀបចំមូលដ្ឋានគ្រឹះជំរុញការទទួលយក និង បរិវត្តកម្មឌីជីថល នៅក្នុងគ្រប់តួអង្គសង្គម ទាំងរដ្ឋ ទាំងពលរដ្ឋ និង ទាំងធុរជន ដើម្បីជំរុញសម្ទុះកំណើនសេដ្ឋកិច្ចថ្មី និង លើកកម្ពស់សុខុមាលភាពសង្គម។

## ជំពូកទី២

## តួនាទី និង ភារកិច្ចរបស់ ក.ស.ឌ.

**មាត្រា២.-**

**ក.ស.ឌ.** មានតួនាទី និង ភារកិច្ច ដូចខាងក្រោមៈ

- កំណត់ចក្ខុវិស័យ និង គោលការណ៍អភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល
- តម្រង់ទិស រៀបចំ និង ដាក់ចេញគោលនយោបាយ និង យុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល ព្រមទាំងកំណត់យន្តការអនុវត្ត តាមដាន ត្រួតពិនិត្យ និង វាយតម្លៃ
- លើកសំណើផ្តល់យោបល់ជូនរាជរដ្ឋាភិបាលលើការរៀបចំច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត ដែលអាចមានកម្មវិបាកលើការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល
- លើកអនុសាសន៍ជូនរាជរដ្ឋាភិបាលលើផែនការវិនិយោគលើគម្រោងអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល
- ដឹកនាំ សម្របសម្រួល និង កសាងភាពជាដៃគូលើកិច្ចសហប្រតិបត្តិការជាតិ និង អន្តរជាតិលើការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល
- ដឹកនាំ សម្របសម្រួល និង ដោះស្រាយការងារនិងបញ្ហាផ្សេងៗ ដែលមានលក្ខណៈអន្តរស្ថាប័នពាក់ព័ន្ធនឹងគ្រប់ទិដ្ឋភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល
- កៀរគរធនធានហិរញ្ញវត្ថុ ធនធានបច្ចេកទេស និង ធនធានមនុស្ស ក្នុងបុព្វហេតុអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល
- ជំរុញការអនុវត្តច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត ព្រមទាំងគោលនយោបាយ យុទ្ធសាស្ត្រ ផែនការមេ កម្មវិធី គម្រោងអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល និង យន្តការអនុវត្តប្រកបដោយប្រសិទ្ធភាព
- ជំរុញ លើកទឹកចិត្ត និង គាំទ្រការចូលរួមលើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថលពីគ្រប់ [illegible]

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

- ជំរុញការកសាងហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បរិវត្តកម្មឌីជីថល ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌី-ជីថល
- កំណត់ក្របខណ្ឌគ្រប់គ្រង និង អភិវឌ្ឍធនធានមនុស្ស ដើម្បីបម្រើតម្រូវការនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល
- ជំរុញការតាមដាន ការត្រួតពិនិត្យ និង ការវាយតម្លៃការអនុវត្តច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត ដោយរៀបចំរបាយការណ៍ជូនរាជរដ្ឋាភិបាល
- តាមដាន ត្រួតពិនិត្យ និង វាយតម្លៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ កម្មវិធី គម្រោងអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល និង យន្តការអនុវត្តប្រកបដោយប្រសិទ្ធភាព ដោយកំណត់សូចនាករសមិទ្ធកម្មគន្លឹះសម្រាប់តាមដានការអនុវត្តនេះ កែសម្រួលវិធានការគោលនយោ-បាយតាមការចាំបាច់ និង រៀបចំរបាយការណ៍ជូនរាជរដ្ឋាភិបាល
- ផ្ដួចផ្ដើម និង កំណត់កម្មវត្ថុនៃការសិក្សាស្រាវជ្រាវ និង រៀបចំទស្សនកិច្ចសិក្សា ទាំងក្នុងប្រទេស និង ក្រៅប្រទេស ដើម្បីទាញយកបទពិសោធ និង ប្រមូលធាតុចូលសំខាន់ៗពាក់ព័ន្ធនឹងការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថលក្នុងតំបន់ និង សកលលោក
- កសាងទំនុកចិត្ត និង ភាពជឿជាក់ពីគ្រប់តួអង្គសង្គមលើប្រព័ន្ធឌីជីថល ដើម្បីឆ្លើយតបទៅនឹងតម្រូវ-ការនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល
- ពិនិត្យ និង សម្រេចឱ្យមានការផ្សព្វផ្សាយឧត្តមានុវត្តន៍ បទពិសោធ ចំណេះដឹង ពុទ្ធិ ទេពកោសល្យ និង ជំនាញអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល
- បំពេញតួនាទី និង ភារកិច្ចដទៃទៀតតាមការប្រគល់ជូនពីប្រមុខរាជរដ្ឋាភិបាល។

## ជំពូកទី៣
## សមាសភាពរបស់ ក.ស.ឌ.

**មាត្រា៣.-**

**ក.ស.ឌ.** មានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| - នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | ប្រធាន |
| - ឧបនាយករដ្ឋមន្ត្រី១រូប | អនុប្រធានប្រចាំការ |
| - រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងការពារជាតិ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | អនុប្រធាន |
| - រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | សមាជិក |

- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ — សមាជិក
- រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម — សមាជិក
- រដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល — សមាជិក
- រដ្ឋមន្ត្រីក្រសួងផែនការ — សមាជិក
- រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា — សមាជិក
- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា — សមាជិក
- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ — សមាជិក
- រដ្ឋមន្ត្រីក្រសួងបរិស្ថាន — សមាជិក
- រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម — សមាជិក
- រដ្ឋមន្ត្រីក្រសួងព័ត៌មាន — សមាជិក
- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ — សមាជិក
- រដ្ឋមន្ត្រីក្រសួងសុខាភិបាល — សមាជិក
- រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន — សមាជិក
- រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ — សមាជិក
- រដ្ឋមន្ត្រីក្រសួងទេសចរណ៍ — សមាជិក
- រដ្ឋមន្ត្រីក្រសួងកិច្ចការនារី — សមាជិក
- រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ — សមាជិក
- រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ — សមាជិក
- តំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ១រូប — សមាជិក
- ទេសាភិបាលធនាគារជាតិនៃកម្ពុជា — សមាជិក។

**ក.ស.ឧ.** អាចមានសមាសភាពបន្ថែមជាប្រធានស្ថាប័ន ឬ តំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀតនៃរាជរដ្ឋាភិបាល តាមការចាំបាច់។

សមាសភាពជាក់ស្តែងនៃ **ក.ស.ឧ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ ក.ស.ឧ.

**មាត្រា៤.-**

**ក.ស.ឧ.** ត្រូវប្រជុំរៀងរាល់៦(ប្រាំមួយ)ខែម្តង តាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីចាំបាច់ ម្យ៉ាងទៀត **ក.ស.ឧ.** អាចកោះប្រជុំជាវិសាមញ្ញបាន។

នៅក្នុងករណីដែលប្រធាន **ក.ស.ឧ.** អវត្តមាន ឬ មានករណីចាំបាច់ ប្រធាន **ក.ស.ឧ.** អាចផ្ទេរសិទ្ធិជូនអនុប្រធានប្រចាំការ ដើម្បីដឹកនាំកិច្ចប្រជុំ។

សមាជិក **ក.ស.ឌ.** ដែលមិនអាចចូលរួមកិច្ចប្រជុំបាន ត្រូវចាត់ថ្នាក់ដឹកនាំជាន់ខ្ពស់ដែលមានសិទ្ធិសម្រេចក្នុងនាមស្ថាប័នខ្លួន ដើម្បីចូលរួមកិច្ចប្រជុំ និង សម្រេចជំនួស។

**មាត្រា៥.-**

ប្រធាន **ក.ស.ឌ.** ឬ អនុប្រធានប្រចាំការដែលទទួលសិទ្ធិដឹកនាំកិច្ចប្រជុំពីប្រធាន មានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំ មន្ត្រីជាន់ខ្ពស់ តំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ ឬ ឥស្សរជន ដែលមានបទពិសោធ សមត្ថភាព និង ជំនាញវិជ្ជាជីវៈ ចូលរួមផ្តល់យោបល់ក្នុងកិច្ចប្រជុំរបស់ **ក.ស.ឌ.** តាមការចាំបាច់។

**មាត្រា៦.-**

**ក.ស.ឌ.** មានគណៈកម្មាធិការជំនាញចំនួន ៣ ជាសេនាធិការលើការងារបច្ចេកទេស ដូចខាងក្រោម៖

- គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល
- គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល
- គណៈកម្មាធិការសន្តិសុខឌីជីថល។

**មាត្រា៧.-**

គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល បំពេញមុខងារជាសេនាធិការលើការងារបច្ចេកទេស ជូន **ក.ស.ឌ.** នៅក្នុងការដឹកនាំសម្របសម្រួល និង ការជំរុញការកសាង និង ការអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និង សង្គមឌីជីថល។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៨.-**

គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល បំពេញមុខងារជាសេនាធិការលើការងារបច្ចេកទេស ជូន **ក.ស.ឌ.** នៅក្នុងការដឹកនាំសម្របសម្រួល និង ការជំរុញការធ្វើបរិវត្តកម្មឌីជីថលនៃដំណើរការការងាររបស់រាជរដ្ឋាភិបាល។

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៩.-**

គណៈកម្មាធិការសន្តិសុខឌីជីថល បំពេញមុខងារជាសេនាធិការលើការងារបច្ចេកទេស ជូន **ក.ស.ឌ.** នៅក្នុងការដឹកនាំសម្របសម្រួល និង ការជំរុញការគ្រប់គ្រងសន្តិសុខឌីជីថល ដើម្បីការពារអត្ថប្រយោជន៍របស់គ្រប់តួអង្គសង្គមទប់ទល់នឹងការវាយប្រហារគ្រប់រូបភាព ឆ្លើយតបគ្រប់ផ្នែក ទាំងបច្ចេកទេស និង ទាំងកម្លាំងពាក់ព័ន្ធការធានា និង ការពារសន្តិសុខឌីជីថល។

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសន្តិសុខឌីជីថល ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១០.-**

**ក.ស.ឌ.** មានក្រុមប្រឹក្សាយោបល់បច្ចេកវិទ្យាឌីជីថលមួយ ដែលបំពេញមុខងារសម្រាប់ពិគ្រោះ និងផ្តល់យោបល់កម្រិតគោលនយោបាយ សំដៅផ្តល់ជាតុចូល និងជួយភ្ជាប់ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ

ពាក់ព័ន្ធផ្សេងៗ។

ក្រុមប្រឹក្សាយោបល់បច្ចេកវិទ្យាឌីជីថល មានសមាសភាពចម្រុះមកពីដៃគូអភិវឌ្ឍន៍ ស្ថាប័នស្រាវជ្រាវ ស្ថាប័នអប់រំ វិស័យឯកជន និង តួអង្គពាក់ព័ន្ធសំខាន់ៗផ្សេងទៀត តាមការចាំបាច់។

សមាសភាពជាក់ស្តែង ព្រមទាំងតួនាទី និង ភារកិច្ចរបស់ក្រុមប្រឹក្សាយោបល់បច្ចេកវិទ្យាឌីជីថល ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **ក.ស.ឌ.**។

**មាត្រា១១.-**

**ក.ស.ឌ.** មានអគ្គលេខាធិការដ្ឋានមួយ ដែលបំពេញមុខងារជាសេនាធិការ នៅក្នុងការជានាការប្រព្រឹត្ត-ទៅនៃការងាររដ្ឋបាល ការសម្របសម្រួល ការបូកសរុបរបាយការណ៍ និងការរៀបចំកិច្ចប្រជុំរបស់ **ក.ស.ឌ.**។

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ត្រូវបំពេញមុខងារជាអគ្គលេខាធិការដ្ឋាននៃ **ក.ស.ឌ.**។

**មាត្រា១២.-**

**ក.ស.ឌ.** អាចបង្កើតគណៈកម្មការឬក្រុមការងារផ្សេងៗ ដោយសេចក្តីសម្រេចរបស់ប្រធាន **ក.ស.ឌ.** តាមការចាំបាច់។

**មាត្រា១៣.-**

**ក.ស.ឌ.** ត្រូវមានរូបសញ្ញា និង ត្រាដោយឡែករបស់ខ្លួន ដែលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **ក.ស.ឌ.** សម្រាប់បំពេញតួនាទី និង ភារកិច្ចរបស់ខ្លួន។

គណៈកម្មាធិការនីមួយៗ ដូចមានកំណត់ក្នុងមាត្រា៧ មាត្រា៨ និង មាត្រា៩ ខាងលើ មានសិទ្ធិប្រើប្រាស់ត្រាដោយឡែក ដែលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **ក.ស.ឌ.** សម្រាប់បំពេញតួនាទី និង ភារកិច្ចរបស់ខ្លួន។

## ជំពូកទី៥

## ប្រភពធនធាន

**មាត្រា១៤.-**

**ក.ស.ឌ.** មានប្រភពធនធាន ដូចខាងក្រោម៖

- ថវិកាជាតិ
- ថវិកាដៃគូអភិវឌ្ឍន៍
- ប្រភពធនធានជាថវិកា និង ទ្រព្យសម្បត្តិស្របច្បាប់ផ្សេងទៀត។

ការគ្រប់គ្រង ការប្រើប្រាស់ និង ការចាត់ចែងថវិកា និង ទ្រព្យសម្បត្តិខាងលើ ត្រូវអនុលោមតាមច្បាប់ និង លិខិតបទដ្ឋានគតិយុត្តជាធរមាន។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៦.-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ២០២១

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**